# សេវាសាធារណៈ និងបរិស្ថាន Tacoma សំណើអត្រាតម្លៃសម្រាប់អាជីវកម្មឆ្នាំ 2025-2026

សេវាសាធារណៈ Tacoma នឹងបង្ហាញថវិកាសម្រាប់ឆ្នាំ 2025-2026 របស់យើងទៅក្រុមប្រឹក្សាភិបាលសេវាសាធារណៈ និងក្រុមប្រឹក្សាក្រុង Tacoma សម្រាប់រដូវស្លឹកឈើជ្រុះនេះសម្រាប់ការអនុម័ត។ សំណើរបស់យើងរួមមានការកែសម្រួលអត្រាតម្លៃសម្រាប់ថាមពលទីក្រុង Tacoma និងទឹកទីក្រុង Tacoma។

សំណើសម្រាប់សេវាបរិស្ថាន (ទឹកសំណល់ សំណល់រឹង និងទឹកព្យុះភ្លៀង) ត្រូវបានបញ្ជូនទៅគណៈកម្មការសេវាបរិស្ថាន ដែលណែនាំសំណើទាំងនោះទៅក្រុមប្រឹក្សាក្រុង Tacoma ដើម្បីពិនិត្យ និងអនុម័ត។

## ថាមពលនៅ Tacoma

អាជីវកម្មខ្នាតតូចទូទៅ (អត្រា B)

- ការកើនឡើងប្រចាំឆ្នាំ៖ 6.1% ក្នុងឆ្នាំ 2025; 6.1% ក្នុងឆ្នាំ 2026*
- ការកើនឡើងជាមធ្យមប្រចាំខែ៖ $9.79 ក្នុងឆ្នាំ 2025; $10.02 ក្នុងឆ្នាំ 2026*

អាជីវកម្មទូទៅ (អត្រា G)

- ការកើនឡើងប្រចាំឆ្នាំ 3.2% ក្នុងឆ្នាំ 2025; 3.2% ក្នុងឆ្នាំ2026*
- ការកើនឡើងជាមធ្យមប្រចាំខែចំនួន $131 ក្នុងឆ្នាំ 2025; $144 ក្នុងឆ្នាំ2026*

*អត្រាចូលជាធរមាននៅខែមេសាជារៀងរាល់ឆ្នាំ។*

**អត្រានៅសាកលវិទ្យាល័យមានខ្ពស់ជាងនេះបន្តិចបន្តួចដោយសារពន្ធសេវាសាធារណៈចំនួន 6% ពីទីក្រុង U.P.។*

## ទឹក Tacoma

ពាណិជ្ជកម្ម

- សរុប៖ 6.6% ក្នុងឆ្នាំ 2025; 6.6% ក្នុងឆ្នាំ 2026
  - ការគិតថ្លៃថេរ៖ 6.5% ក្នុងឆ្នាំ 2025; 6.5% ក្នុងឆ្នាំ 2026
  - អត្រា CCF (អថេរ)៖ 6.9% ក្នុងឆ្នាំ 2025; 7.0% ក្នុងឆ្នាំ 2026
- ការកើនឡើងជាមធ្យមប្រចាំខែសម្រាប់អតិថិជននៅក្នុងក្រុង Tacoma៖
  - $22.38 ក្នុងឆ្នាំ 2025; $23.89 ក្នុងឆ្នាំ 2026
- ការកើនឡើងជាមធ្យមប្រចាំខែសម្រាប់អតិថិជននៅខាងក្រៅក្រុង Tacoma៖
  - $26.88 ក្នុងឆ្នាំ 2025; $28.64 ក្នុងឆ្នាំ 2026*

ពាណិជ្ជកម្មខ្នាតធំ

- សរុប៖ 9.0% ក្នុងឆ្នាំ 2025; 9.0% ក្នុងឆ្នាំ 2026
  - ការគិតថ្លៃថេរ៖ 6.5% ក្នុងឆ្នាំ 2025; 6.5% ក្នុងឆ្នាំ 2026
  - អត្រា CCF (អថេរ)៖ 9.1% ក្នុងឆ្នាំ 2025; 9.1% ក្នុងឆ្នាំ 2026
- ការកើនឡើងជាមធ្យមប្រចាំខែសម្រាប់អតិថិជននៅក្នុងក្រុង Tacoma៖
  - $1,934.77 ក្នុងឆ្នាំ 2025; $2,109.79 ក្នុងឆ្នាំ 2026
- ការកើនឡើងជាមធ្យមប្រចាំខែសម្រាប់អតិថិជននៅខាងក្រៅក្រុង Tacoma៖
  - $2,321.75 ក្នុងឆ្នាំ 2025; $2,537.71 ក្នុងឆ្នាំ 2026*

*អត្រាចូលជាធរមាននៅខែមករាជារៀងរាល់ឆ្នាំ។*

**អត្រានៅសាកលវិទ្យាល័យមានខ្ពស់ជាងនេះបន្តិចបន្តួចដោយសារពន្ធសេវាសាធារណៈចំនួន 6% ពីទីក្រុង U.P.។*

## សេវាបរិស្ថាន

### ទឹកព្យុះ

2025 – កើនឡើងប្រហែល 8%

2026 – កើនឡើងប្រហែល 8%

### ទឹកសំណល់

2025 – កើនឡើងប្រហែល 3-9%

2026 – កើនឡើងប្រហែល 5-8%

### កាកសំណល់រឹង

**ធុង 20– 300 ហ្គាឡុង**

- 2025 – កើនឡើងប្រហែល 0-8%
- 2026 – កើនឡើងប្រហែល 0-8%

**ប្រអប់ទម្លាក់**

- 2025 – កើនឡើងប្រហែល 3%
- 2026 – កើនឡើងប្រហែល 3%

**ធុងតូចប្រអប់ទម្លាក់**

- 2025 – កើនឡើងប្រហែល 8%
- 2026 – កើនឡើងប្រហែល 8%

**ធុងផ្ទុកខាងមុខ**

- 2025 – កើនឡើងប្រហែល 3%
- 2026 – កើនឡើងប្រហែល 3%

**ធុងតូចផ្ទុកខាងមុខ**

- 2025 – កើនឡើងប្រហែល 8%
- 2026 – កើនឡើងប្រហែល 8%

**ការកែច្នៃឡើងវិញបែបពាណិជ្ជកម្ម**

- 2025 – កើនឡើងប្រហែល 8%
- 2026 – កើនឡើងប្រហែល 8%

*អត្រាចូលជាធរមាននៅខែមករាជារៀងរាល់ឆ្នាំ។*

*អត្រានេះគឺជាអត្រាតម្លៃដំបូង និងអាចផ្លាស់ប្តូរបាន។*

CITY OF Tacoma
STORMWATER SOLIDWASTE WASTEWATER
ENVIRONMENTAL SERVICES DEPARTMENT
TACOMA PUBLIC UTILITIES

# ហេតុអ្វីត្រូវកែតម្រូវអត្រាតម្លៃ?

ក្នុងនាមជាសេវាសាធារណៈ យើងកំណត់អត្រាតម្លៃដើម្បីរ៉ាប់រងថ្លៃចំណាយលើសេវាសំខាន់ៗ។ វារួមបញ្ចូលទាំងថ្លៃដើម្បីផ្តល់សេវាដែលមានសុវត្ថិភាព និងទុកចិត្តបាន ការថែរក្សាប្រព័ន្ធរបស់យើង ការការពារធនធានធម្មជាតិនៅជិតបរិក្ខាររបស់យើង ការអនុលោមតាមបទបញ្ញត្តិ និងការវិនិយោគបង្កើនគុណភាពដែលធ្វើឱ្យសេវាកម្មរបស់យើងកាន់តែប្រសើរ។ ការចំណាយកើនឡើងក្នុងប្រតិបត្តិការ និងការថែរក្សាប្រព័ន្ធរបស់យើង អតិផរណានៃវត្ថុធាតុដើម និងសម្ភារៈផ្គត់ផ្គង់ និងផលប៉ះពាល់ជាបន្តបន្ទាប់ពីការបាត់បង់អតិថិជនទឹកពាណិជ្ជកម្មដ៏ធំបំផុតមួយរបស់យើង គឺជាកត្តាចម្បងដែលប៉ះពាល់ដល់អត្រាតម្លៃរបស់យើងសម្រាប់ឆ្នាំ 2025 និងឆ្នាំ 2026។ ថ្លៃចំណាយលើការសាងសង់បរិក្ខារផ្តល់សេវាសាធារណៈជាមធ្យមបានកើនឡើងជាង 20-30% ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ។ យើងត្រូវតែបង្កើនអត្រាតម្លៃរបស់យើងដើម្បីបង្គ្រប់លើការចំណាយដែលកាន់តែមានខ្ពស់។ តាមរយៈអត្រាតម្លៃកើនឡើងបន្តិចម្តងៗតាមពេលវេលានោះ យើងអាចទប់ស្កាត់ការកើនឡើងដ៏ច្រើនខណៈដែលយើងនៅតែផ្តល់ជូនសេវាកម្មដែលអ្នកពឹងផ្អែកបាន។

## ការកើនឡើងនៃថ្លៃចំណាយពីអតិផរណា

ដូចជាអតិថិជនរបស់យើងដែរ យើងកំពុងតែមានការកើនឡើងថ្លៃចំណាយលើការធានារ៉ាប់រង សម្ភារៈ និងគ្រឿងផ្គត់ផ្គង់។ ជាឧទាហរណ៍ តម្លៃនៃការទិញអគ្គិសនីដើម្បីធានាបាននូវភាពជឿជាក់ និងបំពេញតម្រូវការកំពុងកើនឡើង 13%។ ឧទាហរណ៍មួយទៀតគឺ ការចំណាយលើរថយន្តប្រមូល CNG របស់យើងសម្រាប់សំណល់រឹងបានកើនឡើងជាង 25% ក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ។

## កង្វះខ្សែសង្វាក់ផ្គត់ផ្គង់

ការពន្យារពេល និងការលំបាកក្នុងការទិញឧបករណ៍បណ្តាលឱ្យមានការកើនឡើងថ្លៃចំណាយ និងធនធានដែលមានកម្រិត។ ឧទាហរណ៍ ការផ្លាស់ប្តូរត្រង់ស្វូឡើងថ្លៃបន្ថែម 282% ច្រើនជាងប៉ុន្មានឆ្នាំមកនេះ។

## ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ

យើងត្រូវថែរក្សា និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដែលមានសភាពចាស់ ដើម្បីសុវត្ថិភាព និងភាពជឿជាក់។ ឧទាហរណ៍ដ៏សំខាន់មួយគឺគម្រោងផ្លាស់ប្តូរលូទឹកសម្រាប់ច្រើនឆ្នាំតាមបណ្តោយផ្លូវ Puyallup Avenue ដែលប៉ះពាល់ដល់ទាំងទឹកព្យុះភ្លៀង និងទឹកស្អុយ។

## គម្រោងសន្សំសំចៃថ្លៃចំណាយ

យើងខ្ញុំដឹងថាអត្រាតម្លៃមានផលប៉ះពាល់ដល់អ្នក។ យើងខិតខំធ្វើការដើម្បីទប់ស្កាត់ការចំណាយរបស់យើង ដែលជួយយើងផ្តល់នូវអត្រាទាបបំផុតបានខ្លះក្នុងតំបន់។ នេះធ្វើឱ្យសេវាកម្មកាន់តែមានតម្លៃសមរម្យសម្រាប់មនុស្សគ្រប់គ្នានៅក្នុងសហគមន៍របស់យើង។

នេះគឺជាឧទាហរណ៍មួយចំនួនអំពីរបៀបដែលយើងកាត់បន្ថយការចំណាយ៖

- ការស្វែងរកជំនួយពីរដ្ឋ និងសហព័ន្ធ ដើម្បីផ្តល់ជំនួយដល់គម្រោងដែលធ្វើឱ្យបទពិសោធរបស់អតិថិជនកាន់តែប្រសើរ រួមមាន៖
  - ជំនួយ Bureau of Reclamation Water Smart Grant ដើម្បីទូទាត់ថ្លៃចំណាយពីឧបករណ៍វាស់ទឹកជឿនលឿន។
  - American Public Power Association – Demonstration of Energy & Efficiency Developments បានបង់ប្រាក់សម្រាប់គម្រោងសាកល្បង Heat Pump Water Heating (កាបូមយកកម្តៅពីកម្តៅទឹក) នៅក្នុងអាគារពហុគ្រួសារនៃអាជ្ញាធរ Tacoma Housing Authority។
  - ក្រសួង WA Department of Commerce (ក្រុមប្រឹក្សាភិបាលការងារសាធារណៈ FY2023) ជួយរ៉ាប់រងថ្លៃចំណាយលើស្ថានីយ៍បូមទឹកថ្មីនៅ Fennel Creek។
- ការផ្តល់ហិរញ្ញប្បទានឡើងវិញដល់បំណុល និងមូលបត្របំណុលរបស់យើងនៅអត្រាទាបជាងមុន ដូច្នេះហើយយើងអាចបង់ប្រាក់តិចជាងមុនសម្រាប់ការប្រាក់។
- ការកែច្នៃ និងលក់ឧបករណ៍ និងទ្រព្យសម្បត្តិដែលយើងលែងត្រូវការ។
- បង្កើនការលក់ថាមពលនិងទឹកដែលលើសតម្រូវការរបស់យើងទៅឱ្យផ្នែកសេវាសាធារណៈផ្សេងទៀត។
- ការអនុវត្តដំណើរការថ្មីមួយដែលមានប្រសិទ្ធភាពជាងមុនសម្រាប់ការគណនាការប្រើប្រាស់ទឹកសម្រាប់វិក្កយបត្រទឹកសំណល់ ដែលកាត់បន្ថយពេលវេលារបស់បុគ្គលិកក្នុងការចេញវិក្កយបត្រ។

## វិធីគ្រប់គ្រងការទូទាត់របស់អ្នក

យើងផ្តល់ជូននូវវិធីជាច្រើនសម្រាប់អាជីវកម្មគ្រប់ទំហំដើម្បីគ្រប់គ្រងវិក្កយបត្រប្រើប្រាស់របស់ពួកគេ ។ ពីការគ្រប់គ្រងគណនីសេវាសាធារណៈច្រើនដល់ធនធាននានាសម្រាប់អ្នកគ្រប់គ្រងអចលនទ្រព្យ និងអចលនទ្រព្យពហុគ្រួសារ ដល់ប្រតិបត្តិករសេវាកម្មអតិថិជន និងគណនីប្រចាំការសម្រាប់អតិថិជនអាជីវកម្ម យើងជួយអ្នកបានគ្រប់ជ្រុងជ្រោយ។

## វិធីគ្រប់គ្រងការប្រើប្រាស់អគ្គិសនី និងទឹករបស់អ្នក

ការអភិរក្សថាមពល និងទឹកអាចកាត់បន្ថយការប្រើប្រាស់របស់អ្នក កាត់បន្ថយការចំណាយ និងផ្តល់អត្ថប្រយោជន៍ដល់បរិស្ថាន។ យើងផ្តល់ជូននូវវិធីជាច្រើនដើម្បីសន្សំសំចៃដោយការដំឡើងកម្រិតឧបករណ៍ដែលកាត់បន្ថយការប្រើប្រាស់ដូចជាភ្លើងបំភ្លឺ HVAC ប្រព័ន្ធធារាសាស្រ្តឆ្លាតវៃនិងច្រើនទៀត។

## របៀបដែលអ្នកអាចចូលរួមបាន

- អានសំណើថវិការបស់យើងតាមអនឡាញ។
- ចូលរួមការប្រជុំសាធារណៈ និងព្រឹត្តិការណ៍ផ្សព្វផ្សាយរបស់យើង រួមទាំងសវនាការសាធារណៈនៅឯកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសេវាសាធារណៈនៅថ្ងៃទី 9 ខែតុលា ឆ្នាំ 2024 និងកិច្ចប្រជុំក្រុមប្រឹក្សាក្រុងនៅពេលក្រោយក្នុងរដូវស្លឹកឈើជ្រុះនេះ។
- បញ្ជូនសំណួរ និងមតិយោបល់របស់អ្នកតាមសំណុំបែបបទអនឡាញរបស់យើង។
- ទាក់ទងបុគ្គលិកកាន់គណនីរបស់អ្នក។

**សូមចូលមើល MyTPU.org/Rates សម្រាប់ព័ត៌មានលម្អិត។**